Washington State Department of
Labor & Industries

# សេចក្តីជូនដំណឹងដល់និយោជិត

**វាជាច្បាប់! និយោជកត្រូវតែបិទសេចក្តីជូនដំណឹងនេះនៅកន្លែងដែលនិយោជិតអាចអានវាបាន។**
(ផ្នែក 51.14.100 នៃក្រមស្តីពីរដ្ឋដែលបានកែប្រែ) (Revised Code of Washington 51.14.100)

## ប្រសិនបើរបួសការងារកើតឡើង

និយោជករបស់អ្នកមានស្វ័យធានារ៉ាប់រង។ អ្នកមានសិទ្ធិទទួលបានអត្ថប្រយោជន៍ទាំងអស់ដែលទាមទារដោយច្បាប់ស្តីពីសំណងរបស់កម្មករនៃរដ្ឋ Washington (ធានារ៉ាប់រងឧស្សាហកម្ម)។ អត្ថប្រយោជន៍រួមមានការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការជំនួសប្រាក់ឈ្នួលមួយផ្នែក ប្រសិនបើអ្នកខកខានការងារ។ ក្រសួងការងារ និងឧស្សាហកម្ម (Department of Labor & Industries, L&I) គ្រប់គ្រងច្បាប់ទាំងនេះ។

## អ្វីដែលអ្នកត្រូវធ្វើ

**រាយការណ៍ពីការរងរបួសរបស់អ្នក។** ប្រសិនបើមានរបួស មិនថារបួសស្រាលប៉ុនណាទេ សូមទាក់ទងបុគ្គលដែលមានរាយបញ្ជីនៅលើបណ្ណប្រកាសនេះ។

**ទទួលយកការថែទាំផ្នែកវេជ្ជសាស្ត្រ។** សម្រាប់ការព្យាបាលដំបូងរបស់អ្នក សូមទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីព្យាបាលរបួសរបស់អ្នក។ សម្រាប់ការថែទាំបន្ត សូមទៅជួបវេជ្ជបណ្ឌិតនៅក្នុងបណ្តាញវេជ្ជសាស្ត្រ L&I។ (ស្វែងរកអ្នកផ្តល់សេវាក្នុងបណ្តាញតាមរយៈ **Lni.wa.gov/FindADoc** [តំណក្នុងការបោះពុម្ពផ្សាយនេះអាចមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ])។

អ្នកផ្តល់សេវាថែទាំសុខភាពមានលក្ខណសម្បត្តិគ្រប់គ្រាន់រួមមាន៖ គ្រូពេទ្យផ្នែកវេជ្ជសាស្ត្រ ផ្នែកព្យាបាលឆ្អឹង ផ្នែកព្យាបាលឆ្អឹងខ្នងដោយការចាប់សរសៃ ផ្នែកព្យាបាលរោគតាមលក្ខណៈធម្មជាតិ និងគ្រូពេទ្យផ្នែកព្យាបាលជើង គ្រូពេទ្យធ្មេញ អ្នកឯកទេសពិនិត្យភ្នែកនិងប្រើឡង់ទី គ្រូពេទ្យភ្នែក ជំនួយការគ្រូពេទ្យ អ្នកជំនាញគិលានុបដ្ឋាយិកាដែលបានចុះឈ្មោះកម្រិតខ្ពស់ និងសម្រាប់ការទាមទារសម្រាប់តែលក្ខខណ្ឌថែទាំសុខភាពផ្លូវចិត្តប៉ុណ្ណោះ អ្នកចិត្តវិទ្យា។

**ដាក់ពាក្យបណ្តឹងទាមទារសំណងរបស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។** សម្រាប់ការរងរបួសនៅកន្លែងធ្វើការ អ្នកត្រូវដាក់ពាក្យបណ្តឹងជាមួយនិយោជករបស់អ្នកក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃដែលរបួសបានកើតឡើង។ សម្រាប់ជំងឺទាក់ទងនឹងការងារ អ្នកត្រូវតែដាក់ពាក្យបណ្តឹងទាមទារក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីកាលបរិច្ឆេទដែលអ្នកផ្តល់សេវារបស់អ្នកផ្តល់ដំណឹងជូនអ្នកជាលាយលក្ខណ៍អក្សរថាអ្នកមានលក្ខខណ្ឌទាក់ទងនឹងការងារ។

## ដើម្បីរាយការណ៍ពីការរងរបួស៖

ប្រសិនបើអ្នករងរបួសនៅកន្លែងធ្វើការ ឬមានរបួសទាក់ទងនឹងការងារ សូមរាយការណ៍ភ្លាមៗទៅកាន់បុគ្គលខាងក្រោម៖

**ឈ្មោះ៖** ______________________________

**ទូរសព្ទ៖** ______________________________

**អ៊ីមែល៖** ______________________________

សូមទាក់ទងមន្ត្រីទទួលបណ្តឹងសាធារណៈ សម្រាប់កម្មករដែលរងរបួសមានស្វ័យធានារ៉ាប់រងតាមលេខ 1-888-317-0493 ដើម្បីទទួលបានជំនួយជាមួយបញ្ហាសំណងរបស់កម្មករ។

*មានជំនួយផ្នែកភាសា និងទម្រង់បែបបទសម្រាប់ជនមានពិការភាពទៅតាមការស្នើសុំផងដែរ។ ទូរសព្ទទៅលេខ 1-800-547-8367។ អ្នកប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍សម្រាប់មនុស្សថ្លង់ (Telecommunication Device for the Deaf, TDD) សូមហៅទៅលេខ 711។ L&I គឺជានិយោជកដែលផ្តល់ឱកាសស្មើគ្នា។*

PUBLICATION F207-037-214 (Cambodian) [04-2025]

**អំពីបណ្ណប្រកាសកន្លែងធ្វើការដែលតម្រូវឱ្យមាន**

*សូមចូលទៅ **Lni.wa.gov/RequiredPosters** ដើម្បីស្វែងយល់បន្ថែមអំពីបណ្ណប្រកាសកន្លែងការងារពី L&I និងទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀត។*

**នៅលើគេហទំព័រ៖ Lni.wa.gov**

Self-Insurance Section
Department of Labor & Industries
PO Box 44890
Olympia WA  98504-4890